## ២. សេចក្តីសម្រេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៨

### សេចក្តីសម្រេចលេខ ០១ សសរ

### ស្តីពី

### ការបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដី និង នគររូបនីយកម្ម ខេត្ត សៀមរាប

* * *

- បានឃើញរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ៣៨ ស.ស.រ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត គណៈកម្មាធិការជាតិរៀបចំទឹកដី និង គោលការណ៍នគរូបនីយកម្មតំបន់ ជុំវិញភ្នំពេញ ខេត្ត ក្រុង ទូទាំងប្រទេស

តាមការពិភាក្សាការងារ នាថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៣ នៅសាលាខេត្តសៀមរាប

### សម្រេច

ប្រការ ១ : អនុគណៈកម្មាធិការមួយត្រូវបានបង្កើតនៅខេត្ត សៀមរាប មានឈ្មោះថា : អនុគណៈកម្មាធិការរៀបចំខេត្ត សៀមរាប ដែលមានទីស្នាក់ការនៅសាលាខេត្ត សៀមរាប ។

ប្រការ ២ : សមាសភាពមាន ÷

- លោកអភិបាលខេត្ត ជាប្រធាន
- លោក អភិបាលខេត្តរង ជាអនុប្រធានអចិន្ត្រៃយ៍
- លោក នាយក សុរិយោដី ជាសមាជិក
- លោក នាយកទេសចរណ៍ ជាសមាជិក
- លោក នាយកគមនាគមន៍ ជាសមាជិក
- លោក នាយកកសិកម្ម ជាសមាជិក
- លោក នាយករៀបចំក្រុង ជាលេខាធិការ

ប្រការ ៣ : អនុគណៈកម្មាធិការនេះ មានភារកិច្ចអនុវត្តតាមការណែនាំជាក់ស្តែង របស់

ប្រធានគណៈកម្មាធិការជាតិ និង លើកសំណើ ដែលមានចែងនៅក្នុងប្រការ ២ នៃសេចក្តីសំរេច លេខ ៣៩ស.ស.រ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៣ ។

ជ. គណៈកម្មាធិការជាតិ

អគ្គលេខា និង ត្រា

ខណ្ឌ ម៉ូលីខណ្ឌ

* * *

## ៣ . សេចក្តីជូនដំណឹង

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៤

### សេចក្តីជូនដំណឹង លេខ ៣១ សជណ.សរ

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

### សូមទូលថ្វាយ និង ជំរាបជូន

ព្រះអង្គម្ចាស់ ឯកឧត្តមរដ្ឋមន្ត្រី ឯកឧត្តមរដ្ឋលេខាធិការនៃ

គ្រប់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

**កម្មវត្ថុ :** ករណីសំណើសុំគោលការណ៍សំរាប់អនុវត្តចំពោះមន្ត្រីរាជការ ដែលសុំអនុញ្ញាតចេញទៅបំពេញបេសកកម្មនៅឯបរទេស ។

**យោង :** - ព្រះរាជចំណាររបស់សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ ចុះថ្ងៃទី ២៨-១២-១៩៩៣

- ចំណាររបស់ឯកឧត្តម នាយករដ្ឋមន្ត្រីទី ២ ចុះថ្ងៃទី ៣១-១២-១៩៩៣

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិង យោងខាងលើទីស្តីការគណៈរដ្ឋមន្ត្រីមានកិត្តិយសទូលថ្វាយ និងជំរាបជូនព្រះអង្គម្ចាស់ ឯកឧត្តមរដ្ឋមន្ត្រី និង ឯកឧត្តមរដ្ឋលេខាធិការជ្រាបថា : រាជរដ្ឋាភិបាលបានឯកភាពប្រគល់ភារកិច្ចថ្វាយព្រះអង្គម្ចាស់ ជូនឯកឧត្តមរដ្ឋមន្ត្រី រដ្ឋលេខាធិការតាមក្រសួងនិងរដ្ឋលេខាធិការដ្ឋានសំរេចដោយផ្ទាល់ ដោយពុំចាំបាច់សុំគោលការណ៍ ពីគណៈរដ្ឋមន្ត្រីទៀតទេ ចំពោះមន្ត្រីរាជការដែលស្ថិតនៅក្រោម ឱវាទក្រសួង រដ្ឋលេខាធិការដ្ឋាន ដែលត្រូវ